# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

# សេចក្តីជូនដំណឹង

## ការពន្យារពេលប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែករូបវិទ្យា ជំនាន់ទី៣ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ថ្នាក់អាហារូបករណ៍សម្រាប់ឆ្នាំសិក្សា២០២០-២០២១

**យោង៖** ប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ១១១០អយក.ប្រ.ក. ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ ស្តីអំពីការបើកវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែករូបវិទ្យា។

ដោយមានកិច្ចសហការរវាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និង Swedish International Development Cooperation Agency (SIDA) របស់ប្រទេសស៊ុយអែត សាលាក្រោយបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញនឹងរៀបចំការប្រឡងជ្រើសរើសនិស្សិតចំនួន១៩នាក់ ឲ្យចូលសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែករូបវិទ្យា ជំនាន់ទី៣ សម្រាប់ឆ្នាំសិក្សា ២០២០-២០២១។ កម្មវិធីនេះត្រូវរៀនជាភាសាខ្មែរ និងភាសាអង់គ្លេស (ថ្នាក់ពេញម៉ោង)។ ទទួលពាក្យចាប់ពីថ្ងៃផ្សាយដំណឹងនេះរហូតដល់ថ្ងៃសុក្រ០១រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែមករា ឆ្នាំ២០២១ ម៉ោង១៦:០០។

**លក្ខខណ្ឌជ្រើសរើស៖**
- បេក្ខជនត្រូវមានសញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្ត្រ ផ្នែករូបវិទ្យា
- មានសមត្ថភាពភាសាអង់គ្លេស អាចប្រើការបានសម្រាប់ការសិក្សា និងស្រាវជ្រាវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

**សំណុំលិខិត៖**
- ប្រវត្តិរូបសង្ខេបមានបិទរូបថតថ្មី ៤ x ៦ និងពាក្យសុំប្រឡង — ០១ច្បាប់
- សញ្ញាបត្របរិញ្ញាបត្ររូបវិទ្យាមានបញ្ជាក់ពីរាជធានី ខណ្ឌ ឬស្រុក ឬគ្រឹះស្ថានសិក្សា — ០១ច្បាប់
- ព្រឹត្តបត្រពិន្ទុថ្នាក់បរិញ្ញាបត្ររូបវិទ្យា — ០១ច្បាប់
- រូបថតថ្មី (ផ្ទៃពណ៌ខៀវ)ថតចំពីមុខឥតពាក់វ៉ែនតា ទំហំ ៤ x ៦ និងទំហំ ៣ x ៤ — ចំនួន ០៥សន្លឹក

**សម័យប្រឡង៖** ថ្ងៃសុក្រ០៨រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤ ត្រូវនឹងថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១

**វិញ្ញាសាប្រឡង៖**
- រូបវិទ្យាទូទៅ និងរូបវិទ្យាកង់ទិច (៧:៣០ - ១០:៣០)
- ភាសាអង់គ្លេស (វិញ្ញាសាសរសេរ) (១០:៤០ - ១១:៤០)

**អាសយដ្ឋានទាក់ទង៖** សាលាក្រោយបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ បន្ទប់ ៥០៣ ជាន់ទី៥ អគារស្វែម (សភភព)

**ទូរសព្ទទាក់ទង៖** ០៨៥-២៨៩-៧៩១/០៦១-៣០២-០១៧/០១៥-៩៦៦-២៣៤

**បញ្ជាក់៖**
- បេក្ខជនដែលប្រឡងជាប់វិញ្ញាសាសរសេរនឹងត្រូវឆ្លងកាត់ការសម្ភាសជាភាសាអង់គ្លេស ពីកម្មវិធីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់រូបវិទ្យា នៃសាលាក្រោយបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ដើម្បីធ្វើការវាយតម្លៃបន្ថែមលើកម្រិតភាសាអង់គ្លេស ជំនាញ និង បុគ្គលិកលក្ខណៈ។ បេក្ខជនដែលជាប់ជាស្ថាពរ(វិញ្ញាសាសរសេរនិងសម្ភាសន៍) នឹងទទួលបានអាហារូបករណ៍ ១០០%។
- បេក្ខជនត្រូវបង់សិទ្ធប្រឡងចំនួន ២០ដុល្លារ។

ថ្ងៃពុធ១៥រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២១

**ជ. សាកលវិទ្យាធិការ**
**សាកលវិទ្យាធិការរង**

**ប៉ាល់ ដែស**

មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៣ ៦៤០ អ៊ីមែល: secretary@rupp.edu.kh វេបសាយ: www.rupp.edu.kh